**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.០១៧.៤២១.ពស.ជក

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ៨

យោងតាមសេចក្តីជូនដំណឹងលេខ ធ១.០១៦.០៥៤.ពិសេស ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបអំពីការដេញថ្លៃក្នុងប្រតិបត្តិការ LPCO ដូចតទៅ៖

- កាលបរិច្ឆេទដេញថ្លៃ : ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧
- ពេលវេលាដាក់ដេញថ្លៃ : ពីម៉ោង៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់
- ថ្ងៃប្រសិទ្ធភាពទូទាត់ : ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧
- កាលវសាន : ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨
- ទឹកប្រាក់ដាក់ឲ្យដេញថ្លៃ : ៤០.០០០.០០០.០០០ (សែសិបប៊ីលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ២០០.០០០.០០០ (ពីររយលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអតិបរមា/គ្រឹះស្ថាន : ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន)រៀល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា : ៣%
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដេញថ្លៃជាភាគរយ(ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : NCD (ជារៀលឬដុល្លារ) ត្រូវមានតណប្រតិទានយ៉ាងតិច ៣៦៤ថ្ងៃ។ NCD ជាដុល្លារត្រូវកំណត់ haircut ៥% នៃទឹកប្រាក់ដែលដេញថ្លៃបាន។

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមរយៈសារអេឡិចត្រូនិក bod_lpco@nbc.org.kh ។ ក្នុងករណីដែលសារអេឡិចត្រូនិកមិនដំណើរការ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការ ឲ្យបានមុនម៉ោង១២:០០ នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO ។


សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣/ (៨៥៥-២៣) ៧២២ ២២១ EX ១០៤៨
សារអេឡិចត្រូនិក : lpco_info@nbc.org.kh